ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

អគ្គបញ្ជាការដ្ឋាន

លេខ ០១៣ / ឋ.ឌ. ២០២១

# បទបញ្ជា

## ស្តីពី

## ការអនុវត្តការបិទខ្ទប់ភូមិសាស្ត្ររាជធានីភ្នំពេញ និងក្រុងតាខ្មៅនៃខេត្តកណ្តាល ដើម្បីទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ-១៩

## អគ្គមេបញ្ជាការ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១២៩៨/១៨ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ១៩៩៨ ស្តីពីការបង្កើតអគ្គបញ្ជាការដ្ឋាននៃកងយោធពលខេមរភូមិន្ទ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០១/២៣៧ចុះថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០០១ ស្តីពីការកែសម្រួលតួនាទីភារកិច្ច និងរចនាសម្ព័ន្ធចាត់តាំងអគ្គបញ្ជាការដ្ឋាននៃកងយោធពលខេមរភូមិន្ទ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩៣៣ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងមុខងារ អគ្គមេបញ្ជាការនៃកងយោធពលខេមរភូមិន្ទ
- បានឃើញសេចក្តីសម្រេចលេខ:៨៩/សសរ ចុះថ្ងៃទី១៨ ខែមេសា ឆ្នាំ២០២១ របស់ប្រមុខរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញសារាចរណែនាំលេខ:០០៦/សណន/២០២១ ចុះថ្ងៃទី១៧ ខែមេសា ឆ្នាំ២០២១ របស់ក្រសួងការពារជាតិ
- យោងសេចក្តីត្រូវការចាំបាច់ចំពោះមុខ។

## បញ្ជា

១-មេបញ្ជាការប្រភេទទ័ព ទ័ពជំនាញ នាយកស្ថាប័ន និងសាលាចំណុះអគ្គបញ្ជាការដ្ឋាន នៃកងយោធពលខេមរភូមិន្ទ ត្រូវអនុវត្តឱ្យម៉ឺងម៉ាត់បំផុតនូវសេចក្តីសម្រេចលេខ:៨៩/សសរ របស់ប្រមុខរាជរដ្ឋាភិបាល និងសារាចរណែនាំលេខ:០០៦/សណន/២០២១ របស់ក្រសួងការពារជាតិ ស្តីពីការបិទខ្ទប់ភូមិសាស្ត្ររាជធានីភ្នំពេញ និងក្រុងតាខ្មៅនៃខេត្តកណ្តាល ដើម្បីទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ-១៩។

២-បណ្តាស្ថាប័ននៅអគ្គបញ្ជាការដ្ឋាន មានមុខធ្វើការតែនាយទាហានដែលត្រូវវេនប្រចាំបញ្ជា និងប្រចាំការឱ្យកម្រិតអប្បបរមាតិចបំផុត ដើម្បីធានានិរន្តភាពការងារប្រចាំថ្ងៃ យោធិនដែលរស់នៅក្នុងតំបន់ក្រហម (តំបន់ដែលមានការឆ្លងជំងឺកូវីដច្រើន) ត្រូវអនុវត្តទៅតាមវិធានរបស់អាជ្ញាធរមូលដ្ឋាន ចំពោះកងឯកភាពប្រមូលផ្តុំមិនអនុញ្ញាតឱ្យយោធិនចេញក្រៅអង្គភាពជាដាច់ខាត។

ទីចាត់ការកលយុទ្ធអគ្គបញ្ជាការដ្ឋាន ទូរស័ព្ទ : ០៩៧ ៩៩ ៨៩ ៩៩០ ទូរសារ: ០៧៩ ៧៧៨ ៩០៩ អ៊ីមែល: tacticaldirectorate_hcrcaf@yahoo.com

៣-កងឯកភាពដែលមានភារកិច្ចសហការក្នុងការបិទខ្ទប់នេះ ត្រូវអនុវត្តតាមតួនាទីរបស់ខ្លួនឱ្យម៉ឺងម៉ាត់បំផុត និងការពារខ្លួនកុំឱ្យមានការឆ្លងជំងឺកូវីដ-១៩។

៤-រយៈពេលអនុវត្តចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

៥-នាយកឧទ្ទកាល័យអគ្គបញ្ជាការដ្ឋាន មេបញ្ជាការប្រភេទទ័ព ទ័ពជំនាញ នាយកស្ថាប័ន និងសាលា ចំណុះអគ្គបញ្ជាការដ្ឋាន នៃកងយោធពលខេមរភូមិន្ទ ត្រូវអនុវត្តបទបញ្ជានេះឱ្យមានប្រសិទ្ធភាពខ្ពស់៕

ថ្ងៃ សៅរ៍ ៦ កើត ខែ ពិសាខ ឆ្នាំឆ្លូវ ត្រីស័ក ព.ស២៥៦៤

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែ ឧសភា ឆ្នាំ២០២១

**អគ្គមេបញ្ជាការ**

នាយឧត្តមសេនីយ៍ **វង្ស ពិសេន**

**កន្លែងទទួល៖**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យ សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ទីស្តីការក្រសួងមហាផ្ទៃ
- អគ្គស្នងការដ្ឋាននគរបាលជាតិ
- ឯកឧត្តម លោកជំទាវ អគ្គមេបញ្ជាការរង
- អគ្គលេខាធិការដ្ឋានក្រសួងការពារជាតិ
  (ដើម្បីជូនជ្រាប)
- ស្ថាប័នកងឯកភាពដូចមានក្នុងចំណុច៥
  (ដើម្បីសហការអនុវត្ត)
- ឯកសារ កាលប្បវត្តិ